**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារលិខិតរំលែកមរណទុក្ខ

**ផ្ញើជូន**
**ក្រុមគ្រួសារនៃសពយោធិនពលីក្នុងឧបទ្ទវហេតុផ្ទុះគ្រាប់**
**នៅបញ្ជាការដ្ឋានយោធភូមិភាគទី៣ ក្នុងខេត្តកំពង់ស្ពឺ**

***ក្រុមគ្រួសារសព ជាទីរាប់អាន!***

ខ្ញុំ និងភរិយា ពិតជាមានសេចក្តីក្តុកក្តួលរំជួលចិត្ត និងសោកស្តាយឥតឧបមាដោយបានទទួលដំណឹងអំពីពលិកម្មរបស់យោធិននៃកងយោធពលខេមរភូមិន្ទចំនួន២០នាក់ ក្នុងឧបទ្ទវហេតុផ្ទុះគ្រាប់ នៅបញ្ជាការ ដ្ឋានយោធភូមិភាគទី៣ ក្នុងខេត្តកំពង់ស្ពឺ កាលពីថ្ងៃសៅរ៍ ៤រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង១៤.២៥នាទីរសៀល។

ក្នុងវេលាប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងភរិយា សូមចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារនៃសពយោធិនពលីទាំងអស់ ក៏ដូចជានាយទាហាន នាយទាហានរង និងពលទាហានទាំងអស់នៃយោធភូមិភាគទី៣ និងតំបន់ប្រតិបត្តិការសឹករងខេត្តកោះកុង ដែលបានបាត់បង់ស្វាមីប្រកបដោយសង្គហធម៌ចំពោះភរិយា, បាត់បង់ឪពុកប្រកបដោយព្រហ្មវិហារធម៌ចំពោះបុត្រាបុត្រី និងបាត់បង់យុទ្ធមិត្តដ៏អង់អាចក្លាហាន ដែលតែងបានចូលរួមធ្វើពលិកម្មគ្រប់បែបយ៉ាងប្រកបដោយឆន្ទៈមនសិការដ៏មោះមុត ក្នុងបុព្វហេតុបម្រើជាតិ សាសនា ព្រះមហាក្សត្រ និងការពារបូរណភាពទឹកដីជារៀងរហូតមក។

ជាមួយគ្នានេះ ខ្ញុំ និងភរិយា សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធយោធិនពលីទាំង២០នាក់ សូមឆាប់បានយានយកកំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ក្រុមគ្រួសារនៃសពយោធិនពលីទាំង២០នាក់ ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ និងភរិយា។

ថ្ងៃសៅរ៍ ៤រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៤
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**